# ការដាក់ពាក្យ ស្នើសុំហិរញ្ញប្បទាន

សូមអញ្ជើញមកកាន់សាខាណាមួយ
របស់ធនាគារយើងខ្ញុំ ឬទំនាក់ទំនងមកកាន់
ទូរស័ព្ទលេខ 096 811 1118

មន្រ្តីជំនាញនឹងប្រឹក្សាយោបល់ហើយ
ជួយរៀបចំសំណើសុំហិរញ្ញប្បទានជូនលោកអ្នក

ឬ

អាចចុះឈ្មោះស្នើសុំហិរញ្ញប្បទានតាមរយៈអនឡាញ
ដោយគ្រាន់តែចូលទៅកាន់៖
www.smebankcambodia.com.kh

*លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្តន៍
*ធនាគាររក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌនានា
ដោយពុំចាំបាច់ជូនដំណឹងជាមុន។

## ការិយាល័យទំនាក់ទំនងអតិថិជន

096 811 1118

Scan above QR code
to follow our Social Media

info@smebankcambodia.com.kh
smebankcambodia.com.kh



# គម្រោងហិរញ្ញប្បទានវិស័យឌីជីថល និងទំនើបកម្ម (CDAS)

smebankcambodia.com.kh



# គម្រោងហិរញ្ញប្បទាន វិស័យឌីជីថល និងទំនើបកម្ម

**គម្រោងហិរញ្ញប្បទានវិស័យឌីជីថល និងទំនើបកម្ម** ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់ការគាំទ្រដល់ម្ចាស់សហគ្រាសស្ថិតក្នុងវិស័យឌីជីថល និងទំនើបកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈគម្រោងហិរញ្ញប្បទានដែលមានលក្ខខណ្ឌអនុគ្រោះ។

## អត្ថប្រយោជន៍

- ផ្តល់ជូននូវអត្រាការប្រាក់ដែលមានភាពប្រកួតប្រជែង
- គម្រោងហិរញ្ញប្បទានដែលមានរយៈពេលវែង
- តម្រូវការទ្រព្យធានាសមស្រប
- បង្កើនប្រសិទ្ធភាព និងផលិតភាពអាជីវកម្ម

## លក្ខណៈពិសេស

- **ទំហំហិរញ្ញប្បទាន៖** រហូតដល់ ២,០០០ លានរៀល ឬ ៥០០,០០០ ដុល្លារអាមេរិក
- **រូបិយប័ណ្ណ៖** ប្រាក់រៀល ឬ ប្រាក់ដុល្លារអាមេរិក
- **គោលបំណង៖** ប្រើប្រាស់ជាទុនបង្វិល ឬទុនវិនិយោគ
- **អត្រាការប្រាក់ប្រចាំឆ្នាំ៖** ចាប់ពី ៥.៨៨%
- **រយៈពេលហិរញ្ញប្បទាន៖** រហូតដល់ ៧ឆ្នាំសម្រាប់ទុនបង្វិល ឬ ១០ឆ្នាំសម្រាប់ទុនវិនិយោគ
- **ទ្រព្យធានា៖** ទំហំហិរញ្ញប្បទានរហូតដល់ ៧០% នៃតម្លៃទ្រព្យធានាសម្រាប់ប្លង់ទន់ ឬ រហូតដល់ ៨០% នៃតម្លៃទ្រព្យធានាសម្រាប់ប្លង់រឹង

## ឯកសារតម្រូវ

- ឯកសារបញ្ជាក់អត្តសញ្ញាណភាគីអ្នកខ្ចី រួមមាន អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬ លិខិតដែលមានតម្លៃស្មើ
- ឯកសារបញ្ជាក់កម្មសិទ្ធិទ្រព្យធានា
- ឯកសារអាជីវកម្ម រួមមាន អាជ្ញាបណ្ណអាជីវកម្ម ប័ណ្ណប៉ាតង់ ឬវិញ្ញាបនបត្រចុះបញ្ជី (ប្រសិនបើមាន)
- ឯកសារបញ្ជាក់ចំណូលចំណាយ (ប្រសិនបើមាន)
- របាយការណ៍ហិរញ្ញវត្ថុ (ប្រសិនបើមាន)
- របាយការណ៍ធនាគារ (ប្រសិនបើមាន)
- ឬឯកសារផ្សេងៗទៀត អាស្រ័យទៅតាមប្រភេទអាជីវកម្ម

## លក្ខណៈវិនិច្ឆ័យ

- សហគ្រាសធុនតូច និងមធ្យម ដែលប្រកបអាជីវកម្មពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យា ទំនើបកម្ម ឌីជីថល -ល- ដែលស្ថិតក្នុងប្រទេសកម្ពុជា
- សហគ្រាសធុនតូច និងមធ្យម ដែលមានម្ចាស់ភាគហ៊ុនជាជនជាតិខ្មែរ យ៉ាងហោច ៥១%
- សហគ្រាសធុនតូច និងមធ្យម ដែលស្ថិតក្នុងវិស័យអាទិភាព និងបានចុះបញ្ជីអាជីវកម្ម ត្រូវបានលើកទឹកចិត្ត
- តម្រូវការទ្រព្យធានាដូចជា ដី ឬអគារ

